**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

ក្នុងឱកាសដ៏មហាប្រសើរប្រកបដោយក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាប្រកបដោយភក្តីភាព និងកតញ្ញុតាធម៌ ជូនចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាបិតាសន្តិភាព ដែលបាននិងកំពុងដឹកនាំអភិវឌ្ឍប្រទេសជាតិប្រកបដោយគតិបណ្ឌិត រហូតមានការរីកចម្រើនយ៉ាងចាប់រហ័ស និងច្រើនឥតគណនាលើគ្រប់វិស័យទាំងអស់។ វត្តមាន និងភាពប៉ិនប្រសប់នៃមគ្គុទ្ទេសក៍ភាពដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ** បានធ្វើឱ្យប្រទេសជាតិទទួលបាននូវសុខសន្តិភាពពេញលេញ ឯកភាពជាតិ និងភាតរភាពជាតិ បង្កលក្ខណៈជូនប្រជាជនកម្ពុជាគ្រប់រូបបានរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតយ៉ាងសុខក្សេមក្សាន្តប្រកបដោយសុភមង្គលរៀងៗខ្លួន។

ក្នុងឱកាសប្រកបដោយសិរីសួស្តី នៃអំណរសាទរឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ពិសេសទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** សូមយាងប្រោសប្រទានពរជ័យ បវរសួស្តី សិរីមង្គលគ្រប់ប្រការជូន **សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែឈានឆ្ពោះទៅការរីកចម្រើនថ្មីៗថែមទៀត ជាពិសេសធានាបាននូវសន្តិភាពដ៏រឹងមាំ ភាពសម្បូររុងរឿង និងសុភមង្គលរបស់ប្រជាជនកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សមប្រកបនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ចន្ទ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រំ សុខា